Australian Aid

CAVAC
Innovation
In Agriculture

# កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC)

# សមិទ្ធិផលនានា និងមេរៀនដែលទទួលបាន



កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (CAVAC) បានចាប់ដំណើរការពីឆ្នាំ ២០១០-២០១៥ ដោយទទួលបានថវិកាពីរដ្ឋាភិបាលអូស្ត្រាលីដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈវិធីសាស្ត្រប្រព័ន្ធទីផ្សារ។ គោលដៅនៃកម្មវិធីនេះ គឺដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករតាមរយៈការលើកកម្ពស់តម្លៃនៃផលិតកម្មកសិកម្ម។ កម្មវិធី CAVAC ដំណើរការនៅក្នុងខេត្តគោលដៅចំនួនបី៖ កំពង់ធំ កំពត និងតាកែវ។ កម្មវិធី CAVAC បានបង្កើនសង្វាក់តម្លៃកសិកម្មដើម្បីធានាថាប្រាក់ចំណូលរបស់កសិករដែលមានដីតូចៗមានកំណើនប្រកបដោយនិរន្តរភាពដោយប្រើប្រាស់ថវិកាចំនួន ៤៥.៦លានដុល្លារអូស្ត្រាលី។

## វិធីសាស្ត្រប្រព័ន្ធទីផ្សារ




អន្តរាគមន៍ជាច្រើនរបស់កម្មវិធី CAVAC ពាក់ព័ន្ធនឹងការងារជាមួយវិស័យឯកជន តែគោលដៅចុងក្រោយរបស់កម្មវិធីនៅតែផ្តោតលើការបង្កើនប្រាក់ចំណូលរបស់កសិករដើម្បីកាត់បន្ថយភាពក្រីក្រ។

កម្មវិធី CAVAC ផ្តោតទៅលើវិស័យចំនួនពីរសំខាន់៖

**កសិពាណិជ្ជកម្ម និងប្រព័ន្ធផ្សព្វផ្សាយ ៖** ប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធទីផ្សារដើម្បីបង្កើនឱកាសឲ្យកសិករទទួលបាននូវព័ត៌មាននិងការគាំពារដែលមានអត្ថប្រយោជន៍។

**ធារាសាស្ត្រ និងការគ្រប់គ្រងទឹក ៖** លើកកំពស់ការគ្រប់គ្រងទឹកនៅលើដីស្រែដែលស្រោយស្រពដោយ ប្រព័ន្ធធារាសាស្ត្រ និងទឹកភ្លៀង ដើម្បីឲ្យទិន្នផលដំណាំកើនឡើង។

### ទិន្នន័យសង្ខេប – កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា

| | |
|---|---|
| **ម្ចាស់គម្រោង ៖** | រដ្ឋាភិបាលអូស្ត្រាលី |
| **ចំនួនថវិកា ៖** | ៤៥.៦ លានដុល្លារអូស្ត្រាលី |
| **ថិរវេលា ៖** | ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ |
| **ដៃគូក្នុងរាជរដ្ឋាភិបាលកម្ពុជា ៖** | ក្រសួងធនធានទឹក និងឧតុនិយម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ខេត្តគោលដៅ ៖** | កំពង់ធំ កំពត និងតាកែវ |
| **វិធីសាស្ត្រ ៖** | កម្មវិធី CAVAC បានធ្វើការជាមួយក្រុមហ៊ុនជាច្រើន និងតួអង្គក្នុងទីផ្សារផ្សេងៗទៀតដើម្បីលើកកម្ពស់ការគាំទ្រជាប្រព័ន្ធដល់កសិករ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា។ |
| **អ្នកអនុវត្តគម្រោង ៖** | ក្រុមហ៊ុន Cardno Emerging Markets (Australia) Pty Ltd |

All photos: DFAT

# លទ្ធផល

**ចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥ កម្មវិធី CAVAC បានសាងសង់ប្រព័ន្ធធារាសាស្ត្រចំនួន ២០កន្លែង ដែលពេលបច្ចុប្បន្ននេះបានផ្គត់ផ្គង់ទឹកពេញមួយឆ្នាំដល់កសិករចំនួន ១៩.០០០ គ្រួសារ។ ប្រព័ន្ធធារាសាស្ត្រនេះបានជួយជំរុញឲ្យមានការកើនឡើង ផលិតកម្មស្រូវប្រចាំឆ្នាំជាង ២០០.០០០ តោន ស្មើនឹងតម្លៃប្រមាណ ៤៣លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។**

នៅត្រឹមឆ្នាំ២០១៧ មានការប៉ាន់ប្រមាណទុកថាកម្មវិធី CAVAC នឹងផ្លាស់ប្តូរវិធីសាស្ត្រដាំដុះរបស់កសិករចំនួន ៣៤០.០០០គ្រួសារ។ ការងាររបស់កម្មវិធី CAVAC ទៅលើវិស័យជី ថ្នាំកសិកម្ម និងទីផ្សារធារាសាស្ត្របានធ្វើឲ្យមានការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព។ ក្រុមហ៊ុនលក់ជី និងថ្នាំកសិកម្ម បានផ្លាស់ប្តូរវិធីសាស្ត្រធ្វើអាជីវកម្មរបស់ខ្លួន ដោយបច្ចុប្បន្នពួកគេចាត់ទុកថាទំនាក់ទំនងការងារជាមួយកសិករ ជាយុទ្ធសាស្ត្រអាជីវកម្មដ៏ចាំបាច់មួយ ហើយកសិករក៏បានចាប់ផ្តើមជឿជាក់ថា ក្រុមហ៊ុនជាប្រភពដែលអាចទុកចិត្តបានក្នុងការស្វែងរកយោបល់ និងដំណោះស្រាយ។ ក្នុងវិស័យធារាសាស្ត្រ ការគូរប្លង់ប្រឡាយប្រកបដោយគំនិតច្នៃប្រឌិតថ្មីរបស់កម្មវិធី CAVAC នាពេលបច្ចុប្បន្ន ត្រូវបានចាត់ទុកថាជាគំរូសំរាប់ការស្ថាបនាក្នុងវិស័យធារាសាស្ត្រនាពេលអនាគត។ សមិទ្ធផលសំខាន់ៗរបស់កម្មវិធី CAVAC រួមមានដូចជា ៖

- **ប្រព័ន្ធធារាសាស្ត្រ៖** យ៉ាងហោចណាស់កសិករចំនួន១៩.០០០ គ្រួសារ នាពេលនេះ បានទទួលទឹកពេញមួយឆ្នាំដែលអាចឲ្យពួកគេដាំដំណាំបានពីរ ឬបីដងរៀងរាល់ឆ្នាំ។ កត្តានេះជួយឲ្យកសិករ មានលទ្ធភាពផលិតស្រូវបន្ថែមបានចំនួន២០០.០០០ តោនក្នុងមួយឆ្នាំ ។
- **ជី៖** កម្មវិធី CAVAC ធ្វើការជាមួយបណ្តាក្រុមហ៊ុនជាច្រើនដែលសរុបទៅគ្រប់គ្រងទីផ្សារជីច្រើនជាងមួយភាគបី ដើម្បីផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ស្តីពីការប្រើប្រាស់ជី ដែលអាចជួយឲ្យកសិករបង្កើនទិន្នផលរហូតដល់ ១០ភាគរយ។ ការផ្សព្វផ្សាយតាមរយៈអន្តរាគមន៍របស់ CAVAC បានផ្លាស់ប្តូរវិធីសាស្ត្រដាំដុះរបស់កសិករចំនួនជិត២០០.០០០នាក់។
- **ថ្នាំកសិកម្ម៖** ការផ្លាស់ប្តូរជាប្រព័ន្ធនៃទីផ្សារថ្នាំកសិកម្ម ជាដំណើរការមួយដែលត្រូវបន្ត។ ក្រុមហ៊ុនដៃគូរបស់កម្មវិធី CAVAC ក្តោបក្តាប់កសិករយ៉ាងតិចចំនួន ៥០០.០០០នាក់ក្នុងទីផ្សារ។ សរុបមក រហូតមកដល់ពេលនេះ សកម្មភាពរបស់យើងបានជួយកសិករជាង១៣០.០០០នាក់។
- **ដំណាំបន្លែ៖** តាមរយៈការធ្វើការងារជាមួយក្រុមហ៊ុនចំនួនពីរមានកសិករយ៉ាងតិចចំនួន ១០.០០០នាក់នាពេលបច្ចុប្បន្ន បានទទួលនូវបច្ចេកវិទ្យាថ្មីៗ ហើយកសិករចំនួន ៤.៥០០គ្រួសារត្រូវបានរំពឹងទុកថា កំពុងតែបានអនុវត្តបច្ចេកទេសថ្មីនេះ។
- **ប្រព័ន្ធផ្សព្វផ្សាយ៖** កម្មវិធី CAVAC ជំរុញប្រព័ន្ធផ្សព្វផ្សាយឯកជននៅក្នុងប្រទេសកម្ពុជា ឲ្យផ្តោតគោលដៅទៅលើកសិករ និងសហគមន៍ជនបទ ជាទស្សនិកជនប្រកបដោយសក្តានុពល។ ខ្សែវីដេអូភាគតាមទូរទស្សន៍ចំនួន ២៦ភាគ ត្រូវបានចាក់ផ្សាយដែលនិយាយអំពីប្រធានបទនានាពាក់ព័ន្ធនឹងកសិករ ដូចជាជី និងថ្នាំកសិកម្ម ហើយមានទស្សនិកជនប្រមាណជាង ២០០.០០០នាក់បានទស្សនា។

## តើអ្វីទៅជាវិធីសាស្ត្រប្រព័ន្ធទីផ្សារ?

ការដោះដូរទំនិញសាមញ្ញៗ ដូចជាការលក់ស្រូវរបស់កសិករ អាចមានភាពស្មុគស្មាញជាងអ្វីដែលយើងយល់ឃើញ ដោយសារវាពាក់ព័ន្ធជាមួយនឹងតួអង្គជាច្រើន ដូចជា អ្នកដឹកជញ្ជូន រោងម៉ាស៊ីនកិនស្រូវ អ្នកលក់ជុំ អ្នកលក់រាយ និងគ្រួសារដែលទិញផលិតផល។

ខ្សែសង្វាក់តម្លៃអាចរីកចម្រើនបាន លុះត្រាតែមានការគាំពារផ្សេងៗ ដូចជាការផ្តល់សេវាកម្ម ធនធាន និងហេដ្ឋារចនាសម្ព័ន្ធ។ ឧទាហរណ៍ក្នុងវិស័យស្រូវអង្ករ ខ្សែសង្វាក់តម្លៃអាចនឹងពឹងផ្អែកលើកត្តានានា ដូចជា សេវាដឹកជញ្ជូន ធារាសាស្ត្រ ជី និងឥណទាន។ កត្តាគាំពារទាំងនេះ អាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រាក់ចំណូលរបស់កសិករដែលទទួលបានពីស្រូវអង្កររបស់ខ្លួន។

ខ្សែសង្វាក់តម្លៃពាក់ព័ន្ធទៅនឹងច្បាប់និងបទប្បញ្ញត្តិផ្សេងៗដែលជះឥទ្ធិពលដល់បរិបទពាណិជ្ជកម្ម និងកំណត់អំណាចនៃអ្នកទិញ និងអ្នកលក់ផងដែរ។

វិធីសាស្ត្រប្រព័ន្ធទីផ្សារមានគោលដៅបង្កើនការលើកទឹកចិត្តដល់ប្រព័ន្ធទីផ្សារឲ្យធ្វើការផ្លាស់ប្តូរ តាមរបៀបផ្សេងៗ ដែលនឹងជួយលើកម្ពស់ផលិតភាព និងប្រាក់ចំណូលសម្រាប់កសិករខ្នាតតូច។

## វិធីសាស្ត្ររបស់កម្មវិធី CAVAC

កម្មវិធី CAVAC គឺជាការវិនិយោគលើកដំបូងរបស់រដ្ឋាភិបាលអូស្ត្រាលីទៅលើវិធីសាស្ត្រប្រព័ន្ធទីផ្សារនៅក្នុងប្រទេសកម្ពុជា។
វិធីសាស្ត្ររបស់កម្មវិធី CAVAC រួមមាន៖

- កំណត់មូលហេតុ(មិនមែនតែរោគសញ្ញា)នៃចំណុចខ្សោយទីផ្សារទេ។ ការធ្វើដូចនេះគឺដើម្បីកំណត់នូវភាពត្រួតស៊ីគ្នានៃផលប្រយោជន៍រវាងកសិករ និងដៃគូរ (ពាណិជ្ជកម្ម)សំខាន់ៗ ដែលនាំឲ្យមានការបង្កើតចេញជាយុទ្ធសាស្ត្រផ្សេង។
- រៀបចំអន្តរាគមន៍រយៈពេលខ្លីដែលនាំមកនូវការផ្លាស់ប្តូរតាមរយៈការលើកទឹកចិត្តភាគីនានា ដូចជាក្រុមហ៊ុនជី ឲ្យផ្លាស់ប្តូរនូវឥរិយាបថរបស់ពួកគេ។ កម្មវិធី CAVAC ធ្វើការក្នុងនាមជាអ្នកសម្របសម្រួលនៅពីខាងក្រោយ ដោយផ្តល់នូវការទទួលខុសត្រូវពេញលេញ និងភាពជាម្ចាស់ដល់ដៃគូរបស់ខ្លួន។
- តម្រូវឲ្យមានការទទួលស្គាល់ភាពប្រែប្រួលឥតឈប់ឈរនៃទីផ្សារដោយត្រូវ កែសម្រួលយុទ្ធសាស្ត្រ និងអន្តរាគមន៍ជាប្រចាំ។
- កម្មវិធី CAVAC គ្រប់គ្រងហានិភ័យតាមរយៈការបង្កើតសកម្មភាពនានា ដោយបញ្ចូលនូវអន្តរាគមន៍ច្រើនប្រភេទ ចំណុចចាប់ផ្តើមទៅក្នុងទីផ្សារផ្សេងៗគ្នា និងដៃគូចំរុះ។ សកម្មភាពការងារដែលល្អត្រូវធ្វើឲ្យទីផ្សារដែលមានសក្តានុពល និងហានិភ័យខ្ពស់មានតុល្យភាពជាមួយនឹងទីផ្សារដែលមិនសូវសកម្ម និងហានិភ័យទាបជាង។

### សារសំខាន់នៃភាពបត់បែន

ទោះបីជាកម្មវិធី CAVAC អនុវត្តន៍វិធីសាស្ត្រប្រព័ន្ធទីផ្សារនៅក្នុងការងារកសិពាណិជ្ជកម្មក៏ដោយ ក៏យើងមិនអាចអនុវត្តបានដែរក្នុងការប្រើប្រាស់វិធីសាស្ត្រនេះសម្រាប់សកម្មភាពធារាសាស្ត្ររបស់យើង។ សម្រាប់ធារាសាស្ត្រ កម្មវិធីបានធ្វើការប្រឹក្សាយោបល់យ៉ាងទូលំទូលាយជាមួយសហគមន៍មូលដ្ឋាន រួចហើយទុកឲ្យពួកគេកំណត់ និងគ្រប់គ្រងអន្តរាគមន៍ដោយខ្លួនឯង។

កម្មវិធី CAVAC តម្រូវឲ្យមានការប្តេជ្ញាចិត្តពិតប្រាកដពីដៃគូរបស់យើងនៅពេលធ្វើការវិនិយោគរួមគ្នាទៅលើការច្នៃប្រឌិតថ្មី និងការផ្លាស់ប្តូរ។ ចំណុចនេះក៏រាប់បញ្ចូលផងដែរនូវតម្លៃរបស់ប្រាក់ដែលបានវិនិយោគ ដោយទទួលស្គាល់ថា ការច្នៃប្រឌិតថ្មី និងការផ្លាស់ប្តូរតែងតែមានហានិភ័យ។

វិធីសាស្ត្រនេះយល់ថាបញ្ហាអភិវឌ្ឍន៍ភាគច្រើនគឺមិនមែនជារឿងបច្ចេកទេសបែបសាមញ្ញនោះទេ ដូច្នេះវាត្រូវការពិចារណាលើបំរែបំរួលរបស់ទីផ្សារ និងស្ថានភាពភាពសង្គមសេដ្ឋកិច្ចជាក់ស្តែង។ គោលការណ៍ទាំងនេះត្រូវបានបញ្ជ្រាបនូវរាល់ការងាររបស់កម្មវិធី CAVAC។



# គោលការណ៍របស់កម្មវិធី CAVAC

មុននឹងកម្មវិធី CAVAC វិនិយោគទៅលើប្រព័ន្ធទីផ្សារ ជាដំបូង កម្មវិធីបានធ្វើការវាយតម្លៃការវិនិយោគដោយធៀបនឹងគោលការណ៍ ចំនួន ៤៖ តម្លៃនៃទឹកប្រាក់ និរន្តរភាព អព្យាក្រឹត្យភាព និង តម្រូវការពិតប្រាកដ។

### ១. តម្លៃនៃទឹកប្រាក់

ប្រសិទ្ធភាពលើការវិនិយោគរបស់កម្មវិធី CAVAC ត្រូវបានវាស់វែងតាមរយៈលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ។ អន្តរាគមន៍ប្រកបដោយភាពជោគជ័យ បានផ្តល់នូវអត្ថប្រយោជន៍ និងផលតបស្នងត្រឡប់ខ្ពស់បំផុតពីការវិនិយោគ។

### ២. និរន្តរភាព

កម្មវិធី CAVAC បានធ្វើការជាមួយអ្នកផ្តល់សេវានានាដែលមានស្រាប់ ដោយផ្អែកលើប្រព័ន្ធទីផ្សារដែលមានរួចហើយ។ ការធ្វើបែបនេះពីព្រោះតែការផ្លាស់ប្តូរ អាចមាននិរន្តរភាព ប្រសិនបើតួអង្គពាក់ព័ន្ធជាអ្នកមានកម្មសិទ្ធ និងតំរូវការពិតប្រាកដចេញពីពួកគេផ្ទាល់។ មុនមានការវិនិយោគណាមួយ កម្មវិធី CAVAC បានពិចារណាករណីពាណិជ្ជកម្ម និងឆន្ទៈរបស់ដៃគូ (ឬអ្នកផ្តល់សេវាកម្មគាំទ្រ) ដើម្បីវិនិយោគរួមគ្នា។ ការយល់របស់យើងអំពីនិរន្តរភាព មិនមែនមានន័យថាស្ថាប័ន និងការអនុវត្តនានា ត្រូវរក្សាជាដដែលនោះទេ ៖ នៅក្នុងករណីខ្លះ ការផ្លាស់ប្តូរ ឬការបំពេញបន្ថែមដល់ស្ថាប័នអាចជាការរីកចំរើនវិជ្ជមានមួយ។ និរន្តរភាពមានន័យថាធនធានសំខាន់ៗសម្រាប់កសិកម្ម (ដីមានជីជាតិ, ទឹក, ជីវចម្រុះ និងការការពារដំណាំតាមបែបធម្មជាតិ) រក្សាបាននូវផលិតភាពរបស់វាស្មើនឹងផលិតភាពដែលវាកំពុងតែមានក្នុងពេលបច្ចុប្បន្ននេះ។

### ៣. អព្យាក្រឹតភាព

អន្តរាគមន៍របស់យើងអាចមានផលប៉ះពាល់ដល់ក្រុមផ្សេងៗគ្នាតាមរបៀបខុសៗគ្នា ៖ បុរស និងស្ត្រី កសិករឬអាជីវកម្មខ្នាតតូច និងខ្នាតធំ និងក្រុមផ្សេងទៀត។ ការអនុវត្តន៍បច្ចេកទេសផលិតកម្មល្អជាងមុន និងការបង្កើនការលក់ របស់ក្រុមមួយអាចកាត់បន្ថយឱកាសសម្រាប់ក្រុមមួយទៀត។ កម្មវិធី CAVAC មានការប្រុងប្រយ័ត្នយកចិត្តទុកដាក់ដល់ការដើម្បីកាត់បន្ថយជាអប្បរិមានូវលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមានណាមួយទៅលើអ្នកផលិត ដោយជ្រើសរើសយ៉ាងហ្មត់ចត់នូវទីផ្សារមួយចំនួនដែលមានតម្រូវការច្រើនដែលមិនអាចឆ្លើយតបបាន។ សម្រាប់កម្មវិធី CAVAC ដើម្បីក្លាយជាដៃគូរដែលទុកចិត្តបាន អព្យាក្រឹត្យភាពមានសារសំខាន់ណាស់ ជាពិសេសពីព្រោះតែគោលដៅគន្លឹះរបស់កម្មវិធីគឺដើម្បី “ការចម្លងតាមគ្នា” របស់តួអង្គពាក់ព័ន្ធឲ្យបានច្រើនបំផុតដែលអាចធ្វើទៅបាន ដើម្បីបង្កើនជាអតិបរមានូវគោលការណ៍តម្លៃនៃទឹកប្រាក់ផ្ទាល់របស់យើង។ កម្មវិធី CAVAC យកចិត្តទុកដាក់ខ្ពស់ដើម្បីធ្វើឲ្យប្រាកដថាការគាំទ្រណាមួយមិនបានធ្វើអោយតួអង្គផ្សេងទៀតចេញពីទីផ្សារឡើយ។ ការផ្តល់ជូនលើកដំបូងរបស់កម្មវិធី CAVAC គឺតែងតែផ្តល់ឲ្យដល់ក្រុមហ៊ុនពាក់ព័ន្ធទាំងអស់។ ប្រសិនបើពួកគេមិនទទួលយកភ្លាមៗទេ នោះប្រាកដណាស់ក្រុមហ៊ុនទាំងនោះអាចស្វែងរកការគាំទ្រលើកក្រោយបាន។ ប្រសិនបើក្រុមហ៊ុនក្រោយៗស្វែងរកការគាំទ្រ នៅក្នុងទីផ្សារដដែលនោះ យើងនឹងស្នើសុំពួកគេឲ្យជួយចេញការចំណាយក្នុងការធ្វើសកម្មភាពច្រើនជាងអ្នកមុនៗ នេះជាការទូទាត់ហានិភ័យ ដែលអាចមានចំពោះក្រុមហ៊ុនទីមួយ។

### ៤. មានតម្រូវការពិតប្រាកដ

កម្មវិធីត្រូវបានរៀបចំឡើងស្របតាមតម្រូវការពិតប្រាកដ ពោលគឺឆ្លើយតបទៅនឹងការស្នើសុំការគាំទ្រ និងមិនព្យាយាមផ្តល់ដំណោះស្រាយឲ្យក្រុមហ៊ុនឡើយ។ យ៉ាងនេះក្តី នៅក្នុងរយៈពេលពីរបីឆ្នាំដំបូង កម្មវិធីបានស្វែងរកប្រភពដៃគូយ៉ាងសកម្ម ដោយផ្តល់អាទិភាពដល់ក្រុមនិងទីកន្លែងជាក់លាក់ ហើយធ្វើការជាមួយដៃគូទាំងនោះដើម្បីរៀបចំឯកសារសំណើរ។ ខណៈដែលភាពជឿជាក់ចំពោះកម្មវិធី CAVAC កើនឡើង មានអ្នកត្រូវការយើងកាន់តែច្រើនក្នុងការគាំទ្រសកម្មភាពផ្សេងៗ ដែលផ្តល់ផលប្រយោជន៍ទាំងក្រុមហ៊ុន និងកសិករ។

### ការគ្រប់គ្រងបែបបន្ស៊ាំ

គម្រោងមួយចំនួនដែលមានមហិច្ឆតាផ្លាស់ប្តូរជាប្រព័ន្ធតែងជួបប្រទះនូវបញ្ហាប្រឈមផ្សេង ពីអន្តរាគមន៍បែបប្រពៃណី។ ប្រសិនបើប្រព័ន្ធទីផ្សារត្រូវបានកំណត់ក្របខណ្ឌថាជាប្រព័ន្ធស្មុគស្មាញ នោះវិធីជាក់លាក់ដើម្បីដោះស្រាយឲ្យមានប្រសិទ្ធភាព គឺពិបាកក្នុងការព្យាករណ៍ទុកណាស់។ មូលហេតុដែលទីផ្សារ មិនដំណើរការពេញលេញល្អអាចបណ្តាលមកពីបញ្ហាអំណាចដែលពិបាកដោះស្រាយដោយសារវប្បធម៌ និងទំនៀមទំលាប់។ ដើម្បីដោះស្រាយបញ្ហា ឬធ្វើការជាមួយនឹងកត្តាប្រឈមទាំងនេះ ចាំបាច់ត្រូវមានអន្តរាគមន៍ដែលខុសឆ្ងាយពី “ការអភិវឌ្ឍមុនៗ” នៅក្នុងការគ្រប់គ្រងបែបបន្ស៊ាំ ផែនការលម្អិតជាក់លាក់មានការលំបាកខ្លាំងក្នុងការបត់បែន ឲ្យស្របតាមបរិយាកាសផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ហើយជាជម្រើស យើងអាចធ្វើតេស្តសាកល្បងក្នុងពេលដំណាលគ្នា ជាមួយការដោះស្រាយបញ្ហាជាក់លាក់ដែលយើងមិនអាចដឹងមុននូវទំនាក់ទំនងរវាងហេតុ និងផលរបស់វា។
ការគ្រប់គ្រងបែបបន្ស៊ាំពឹងផ្អែកទៅលើដំណើរនៃការផ្តល់ព័ត៌មានត្រឡប់មកវិញដែលជាមធ្យោបាយដើម្បីពន្លឿនការរៀនសូត្រ ដើម្បីឲ្យអ្នកគ្រប់គ្រងអាចកែតម្រូវទិសដៅ និងធនធានឡើងវិញ ដោយមិនចាំបាច់សិក្សាស្រាវជ្រាវលើរាល់ជម្រើសនិមួយៗដែលមាន។



## កសិពាណិជ្ជកម្ម និងប្រព័ន្ធព័ត៌មាន

កម្មវិធី CAVAC មានគោលបំណងជំរុញឲ្យមានការផ្លាស់ប្តូរជាប្រព័ន្ធទៅលើ ទីផ្សារ ផ្គត់ផ្គង់ ផលិតផល ដល់ កសិករ។ យើង ចាប់ផ្តើម ដំណើរការនេះ តាមរយៈការពិភាក្សាជាមួយកសិករ ក្រុមហ៊ុន និង រាជរដ្ឋាភិបាលកម្ពុជា។ ជាដំបូង កម្មវិធី CAVAC បានសង្កេតមើល ចំណុច ខាងក្រោមនេះ ៖

- តើទីផ្សារដំណើរការយ៉ាងដូចម្តេច?
- តើមានឧបសគ្គអ្វីខ្លះ ដែលកសិករ និងក្រុមហ៊ុនអាជីវកម្មជួបប្រទះ?
- តើឱកាសរីកចម្រើនមានអ្វីខ្លះ?

លក្ខណៈពិសេសនៃវិធីសាស្ត្ររបស់យើងគឺថា បើទោះបីជារាល់សកម្មភាពរបស់យើងត្រូវបានរៀបចំឡើងដើម្បីជួយកសិករ ក៏ជាទូទៅយើងមិនធ្វើការដោយផ្ទាល់ជាមួយនឹងកសិករឡើយ។ ផ្ទុយមកវិញ យើងធ្វើការច្រើនជាមួយនឹង បណ្តាក្រុមហ៊ុនដែលផ្គត់ផ្គង់ផលិតផល និងសេវាកម្មដល់កសិករ។ កម្មវិធី CAVAC បានធ្វើការជាមួយអ្នកផលិតគ្រាប់ពូជ ក្រុមហ៊ុន និងអ្នកលក់ជីថ្នាំកសិកម្ម ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឈ្មួញទិញ/លក់ អ្នកនាំចេញ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ស្ថាប័នស្រាវជ្រាវ សមាគមន៍កសិករ និង បណ្តាទីភ្នាក់ងាររបស់រដ្ឋាភិបាល។

កម្មវិធី CAVAC បានបង្កើតនូវភាពជាដៃគូ និងសកម្មភាពផ្សេងៗ ដែលក្នុងនោះ តួអង្គពាក់ព័ន្ធទាំងអស់បានទទួលអត្ថប្រយោជន៍ពីការ ដោះស្រាយរាល់ឧបសគ្គដែលរាំងស្ទះដល់ការរីកលូតលាស់។ ការច្នៃប្រឌិតថ្មីៗជាមួយនឹងវិស័យឯកជន ត្រូវបានរៀបចំឡើងដើម្បីជួយធ្វើឲ្យប្រសើរឡើង នូវអាជីវកម្មរបស់ពួកគេ ទន្ទឹមនឹងនោះវាក៏បានជួយ ដល់កសិករ ឲ្យទទួលបាន នូវដំណោះស្រាយប្រសើរជាងមុនសម្រាប់ការដាំដុះផងដែរ។

កម្មវិធី CAVAC បានធ្វើការជាមួយទីផ្សារ និងអនុវិស័យជាច្រើន នៅកំឡុងពេលដំណើរការកម្មវិធី ហើយនិងបង្រួមការយកចិត្តទុកដាក់បន្តិចម្តងៗ ដោយផ្តល់អាទិភាព ទៅលើវិស័យសំខាន់ៗចំនួន៥៖

### ១. ជី

ទីផ្សារជី បានផ្លាស់ប្តូរ យ៉ាងច្រើន នៅក្នុងរយៈពេលដែលកម្មវិធី CAVAC មានដំណើរការ។ កាលពីដើមឡើយ មានក្រុមហ៊ុនតិចតួចប៉ុណ្ណោះបានផ្តល់ការប្រឹក្សាអំពីផលិតផល និងបច្ចេកទេសជូនដល់កសិករ ដោយទីផ្សារលក់ផលិតផលទូទៅ គឺក្រុមហ៊ុនប្រកួតប្រជែងគ្នាតែលើតម្លៃ និងផ្តល់នូវការគាំទ្របន្ថែមដ៏មានកម្រិតមួយដល់កសិករ។ តែឥឡូវនេះ ក្រុមហ៊ុនភាគច្រើនបានចែកចាយព័ត៌មាន និងផ្តល់ការប្រឹក្សាយោបល់អំពីវិធីសាស្ត្រល្អៗ ក្នុងការប្រើប្រាស់នូវផលិតផលរបស់ពួកគេ។

ការស្រាវជ្រាវរបស់យើងរកឃើញថាកសិករធ្វើស្រែប្រាំងទាំងអស់បានប្រើប្រាស់ជី ហើយកសិករភាគច្រើនក៏បានប្រើប្រាស់ជីក្នុងក្នុងការធ្វើស្រែរដូវវស្សាផងដែរ។

ការសិក្សាដំណាក់កាលដំបូងរបស់យើងនៅក្នុងឆ្នាំ ២០១០ បានបង្ហាញថាកម្រិតចំណេះដឹងរបស់កសិករអំពីរបៀបប្រើប្រាស់ជីឲ្យបានត្រឹមត្រូវមានកំរិតទាបខ្លាំង។

នេះគឺជាឱកាសដ៏សំខាន់ ពីព្រោះការផ្លាស់ប្តូរបច្ចេកទេសប្រើប្រាស់ជីអាចបង្កើនទិន្នផលចាប់ពី ២០ ទៅ ៣០ភាគរយ។ កត្តានេះបាន

ជំរុញឲ្យកម្មវិធី CAVAC បានសហការជាមួយក្រុមហ៊ុនជី ដើម្បីបង្កើនការប្រឹក្សាយោបល់ និងចែករំលែកព័ត៌មានដល់កសិករ ពេលខ្លះវាអាចជាគំរូល្អដល់អ្នកផ្សេងទៀត។ បន្ទាប់ពីការចាប់ផ្តើមសន្សឹមៗ យើងចាប់អារម្មណ៍យ៉ាងខ្លាំងទៅនឹងការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនទាំងនោះ ក្នុងការផ្តល់ការប្រឹក្សាយោបល់ដល់កសិករ អំពីរបៀបប្រើប្រាស់ផលិតផលរបស់ពួកគេឲ្យបានត្រឹមត្រូវ។ ពេលយើងជួយក្រុមហ៊ុនទាំងនោះក្នុងការបង្កើននូវសមត្ថភាពបច្ចេកទេស មានន័យថាយើងបានជួយពួកគេក្នុងការអភិវឌ្ឍអាជីវកម្មដែរ។

ក្រុមហ៊ុនដែលកម្មវិធី CAVAC សហការធ្វើជាដៃគូជាមួយ បានបម្រើកសិករធ្វើ ស្រែចំនួនមួយភាគបីទូទាំងប្រទេសកម្ពុជា ជាទីផ្សារកសិករប្រមាណ ៦០០.០០០គ្រួសារ។ នៅពេលដែលកម្មវិធី CAVAC បញ្ចប់ មានការព្យាករណ៍ទុកថានឹងមានកសិករធ្វើស្រូវរហូតដល់ពីរលាននាក់អាចទទួលបានព័ត៌មានអំពីការប្រើប្រាស់ជី នៅក្បែរសហគមន៍របស់ពួកគេ។ នាពេលបច្ចុប្បន្ន វាបានក្លាយជាការអនុវត្តជាស្តង់ដាររបស់ ក្រុមហ៊ុននានា ក្នុងការលក់ផលិតផលឲ្យកសិករទោះដោយផ្ទាល់ ឬតាមរយៈអ្នកចែកចាយក្តី។



## ២. ថ្នាំកសិកម្ម

កម្មវិធី CAVAC ក៏បានជះឥទ្ធិពលដល់ក្រុមហ៊ុនលក់ថ្នាំកសិកម្ម ក្នុងការផ្តល់ការគាំទ្រកសិករផងដែរ។ នៅក្នុងដំណាក់កាលដំបូងនៃការចុះសង្កេតរបស់កម្មវិធី CAVAC ទីផ្សារថ្នាំកសិកម្ម ត្រូវបានរកឃើញថាដំណើរការខុសប្រក្រតីខ្លាំង។ កសិករបានប្រើប្រាស់ថ្នាំកសិកម្មចម្រុះ និង គ្មាន ព័ត៌មាន គ្រប់គ្រាន់។ វិធានការ ចម្រុះ គ្រប់គ្រង កត្តាចង្រៃ (Integrated Pest Management) ត្រូវបានលើកកម្ពស់យ៉ាងខ្លាំង ដោយរាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយ ប៉ុន្តែវាមិនត្រូវបានកសិករអនុវត្តឲ្យបានទូលំទូលាយនៅឡើយទេ។

អន្តរាគមន៍ដំបូងរបស់យើង នៅក្នុងទីផ្សារនេះ មិនទទួលបានជោគជ័យឡើយ។ ក្រុមហ៊ុនមានភាពស្ទាក់ស្ទើរក្នុងការធ្វើការជាមួយយើង ពីព្រោះផលិតផលរបស់ពួកគេ ពេលខ្លះមិនទាន់ទទួលបានការអនុញ្ញាត ហើយយើងយល់ថាការផ្លាស់ប្តូរណាមួយនៅលើទីផ្សារថ្នាំនេះ គឺត្រូវធ្វើឲ្យមានការផ្លាស់ប្តូរទៅលើបទប្បញ្ញត្តិ ដែលមានស្រាប់ជាមុនសិន។ កម្មវិធី CAVAC បាន ផ្តល់ ថវិកា និង គាំទ្រ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងការរៀបចំឲ្យមានជាសៀវភៅណែនាំការប្រើប្រាស់ថ្នាំ ដែលក្រោយមកត្រូវបានអនុម័តដោយអគ្គនាយកដ្ឋានកសិកម្ម។ នេះគឺជាជំហានមួយដ៏សំខាន់ ពីព្រោះវាអាចជួយឲ្យកម្មវិធី CAVAC ធ្វើការដោយផ្ទាល់ជាមួយក្រុមហ៊ុនទៅលើការបណ្តុះបណ្តាលបុគ្គលិករបស់ពួកគេ។

ការងារពីមុនរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៅក្នុងវិស័យនេះ ក៏បានដាក់បញ្ចូលនៅក្នុងសៀវភៅណែនាំការប្រើប្រាស់ថ្នាំផងដែរ ក្រៅពីនោះក៏មានជំពូក ដែលពន្យល់អំពីរបៀបលាយថ្នាំកសិកម្មអោយមានសុវត្ថិភាព។ សៀវភៅណែនាំនេះក៏ក្លាយជាជាមធ្យោបាយមួយ ក្នុងការទំនាកទំនងការងារជាមួយនឹងសមភាគីរបស់យើង គឺរាជរដ្ឋាភិបាលកម្ពុជា ហើយនិងតួអង្គវិស័យឯកជនក្នុងទីផ្សារថ្នាំកសិកម្ម។ កម្មវិធី CAVAC បានគាំទ្រជាថវិកាដល់ការធ្វើសិក្ខាសាលាជាច្រើនតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីផ្សព្វផ្សាយសៀវភៅណែនាំនេះ។ សៀវភៅណែនេះមានភាពងាយស្រួលប្រើប្រាស់ និងត្រូវបានចែកចាយយ៉ាងទូលំទូលាយ។

### មេរៀនដែលទទួលបាន

- ការពង្រីកការងារ មិនងាយស្រួលធ្វើផែនការជាមុនឡើយ កម្មវិធីចាំបាច់ត្រូវមានភាពបត់បែនឲ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយតបអោយបានឆាប់ រហ័សទៅនឹងឱកាស។
- ធនធានមនុស្ស និងហិរញ្ញវត្ថុចាំបាច់ត្រូវផ្ទេរទៅឲ្យឱកាសដែលលេចឡើងថ្មី។
- ដំណោះស្រាយមិនអាចរៀបចំជាមុនបានឡើយ ដូច្នេះក្រុមការងារត្រូវចូលរួមផ្ទាល់ជាមួយនឹងក្រុមហ៊ុន និងត្រូវរង់ចាំទទួលយកវិធានការនានាដែលអាចធ្វើឡើងបាន។
- ធម្មតាការច្នៃប្រឌិតថ្មី គឺជាការប្រថុយធ្វើអ្វីដែលមិនទាន់ដឹងលទ្ធផលជាមុនឡើយ ហើយតម្រូវឲ្យមានការរៀបចំប្រកបដោយភាពបត់បែន ភាពជាក់ស្តែង និងកិច្ចសន្យា។
- យុទ្ធសាស្ត្រទាមទារអោយមានការឆ្លុះបញ្ចាំងនិងត្រួតពិនិត្យឡើងវិញនូវជាប្រចាំជានិច្ចជាកាលត្រូវរកមើលវិធីសាស្ត្រល្អជាងមុន។
- វិធីសាស្ត្រប្រព័ន្ធទីផ្សារត្រូវការពេលវេលា កម្មវិធីត្រូវការរយៈពេលយ៉ាងតិចណាស់ប្រាំឆ្នាំដើម្បីឲ្យទទួលបានលទ្ធផល។

តាមរយៈអន្តរាគមន៍ និងការប្រឹក្សាយោបល់ផ្សេងទៀតរបស់យើង តាមរយៈ មជ្ឈមណ្ឌលទូរសព្ទដោះស្រាយបញ្ហាកសិករ បានបង្ហាញឲ្យឃើញច្បាស់ថា កត្តាជំងឺនិងសត្វចង្រៃ គឺជាកង្វល់ដ៏ធំរបស់កសិករ ប៉ុន្តែការវិនិច្ឆ័យបញ្ហា និងការរិះរកដំណោះស្រាយដែលល្អបំផុត គឺមានការលំបាកណាស់ចំពោះកសិករ។ ដើម្បីដោះស្រាយបញ្ហានេះ កម្មវិធី CAVAC បានរៀបចំឲ្យមានជាឧបករណ៍វិនិច្ឆ័យមួយដែលអាច តំឡើងក្នុងទូរសព្ទដៃ ហើយវាអាចជួយឲ្យក្រុមហ៊ុននិងបុគ្គលិករបស់គេ អាចកំណត់អត្តសញ្ញាណ កត្តាចង្រៃ និងផ្តល់យោបល់អំពីការព្យាបាលកត្តាចង្រៃទាំងនោះ។

ទោះបីជាអន្តរាគមន៍ពិតប្រាកដនៅក្នុងទីផ្សារថ្នាំកសិកម្មចាប់ផ្តើមតាមក្រោយក៏ដោយ តែការផ្លាស់ប្តូរបានកើតឡើងយ៉ាងឆាប់រហ័ស។ បច្ចេកទេសថ្មីៗ អាចស្វែងរកបាន ហើយក្រុមហ៊ុនដៃគូរបស់យើងបានចែករំលែកនូវការប្រឹក្សាយោបល់អំពីការកំណត់អត្តសញ្ញាណសត្វចង្រៃ និងជំងឺ ក៏ដូចជា វិធីសាស្ត្រព្យាបាលផងដែរ។ ការផ្លាស់ប្តូរទាំងនេះកំពុងតែលុបបំបាត់ថ្នាំគីមីខុសច្បាប់ ប្រកបដោយគ្រោះថ្នាក់ និង ដែលត្រូវប្រើប្រាស់មិនត្រឹមត្រូវ ដោយជំនួសមកវិញនូវថ្នាំកសិកម្មដែល មានសុវត្ថិភាពជាងមុន និងបានចុះបញ្ជីត្រឹមត្រូវ។ ដោយសារអន្តរាគមន៍នេះចាប់ផ្តើមក្រោយគេនៅ CAVAC វាត្រូវការរយៈពេលជាច្រើនឆ្នាំមុននឹងឥទ្ធិពលពេញលេញ អាចមើលឃើញច្បាស់។ លទ្ធផលដែលអាចកើតឡើង ពីការផ្លាស់ប្តូរក្នុងទីផ្សារថ្នាំកសិកម្ម ទៅលើផលិតភាពផលិតរបស់កសិករ ត្រូវបានរំពឹងទុកថាមានទំហំធំធេងជាងទីផ្សារជីទៅទៀត។

### ៣. ដំណាំបន្លែ

នៅក្នុងឆ្នាំ ២០១១ សកម្មភាពមួយនៅក្នុងចំណោមសកម្មភាពដើមដំបូង ដែលអនុវត្តដោយកម្មវិធី CAVAC គឺបានរៀបចំវគ្គ និងផ្តល់នូវការបណ្តុះបណ្តាលដល់អ្នកលក់គ្រាប់ពូជបន្លែនៅក្នុងខេត្តកំពត កណ្តាល និង តាកែវ។ ជាអកុសល ទីតាំង ទាំងនេះស្ថិតនៅខាងក្រៅតំបន់ដាំបន្លែជាលក្ខណៈពាណិជ្ជកម្មសំខាន់។ យើង ដឹងថាអន្តរាគមន៍ លើ ដំណាំបន្លែ ត្រូវ សកម្មភាពខ្លាំង តាមបណ្តាខេត្តដែលក្រុមហ៊ុនលក់គ្រាប់ពូជបន្លែមានទីផ្សារ។ យើងបានព្រមព្រៀងថានឹងផ្លាស់សកម្មភាពពាក់ព័ន្ធនឹងបន្លែចេញក្រៅពីខេត្តគោលដៅចំនួនបីខាងដើម ហើយក្រោយមកយើងបានទាក់ទាញដៃគូចំនួនពីរផ្សេងទៀត ដែលជាក្រុមហ៊ុនលក់គ្រាប់ពូជបន្លែដ៏ធំ នោះគឺក្រុមហ៊ុន East West Seed International និងក្រុមហ៊ុន Pacific Seeds។

ក្រុមហ៊ុន East West Seed International នាពេលឥឡូវនេះ កំពុងតែបង្កើនផលិតភាពរបស់ក្រុមផលិតបន្លែដ៏ធំបំផុតនៅក្នុងប្រទេសកម្ពុជា ដែលមានន័យថាកសិករចំនួន ១០.០០០នាក់ទទួលបានបច្ចេកទេសថ្មីៗ ហើយយ៉ាងតិចណាស់មានកសិករចំនួន ៤,៥០០ នាក់បានចាប់ផ្តើមប្រើប្រាស់បច្ចេកទេសទាំងនោះ។

### ៤. ប្រព័ន្ធផ្សព្វផ្សាយសារគមនាគមន៍

ការវិភាគរបស់កម្មវិធី CAVAC ទៅលើទីផ្សារប្រព័ន្ធផ្សព្វផ្សាយកម្ពុជានៅក្នុងឆ្នាំ ២០១១ បានបង្ហាញថា មានកម្មវិធីកសិកម្មតិចតួចបំផុតនៅលើកញ្ចក់ទូរទស្សន៍ ហើយកម្មវិធីដែលមានទាំងនោះគ្មានភាពទាក់ទាញ និងមានគុណភាពទាប។

ឧបសគ្គមួយចំនួនដែលត្រូវបានកំណត់ មានដូចជា ៖

- ការយល់ដឹងទាបទៅលើសក្តានុពលនៃទំហំទីផ្សារជនបទ ធ្វើអោយការចាប់អារម្មណ៍មានកម្រិតក្នុងការវិនិយោគទៅលើកម្មវិធីនានា។
- ខ្វះការស្រាវជ្រាវ ដើម្បីពិនិត្យមើលទម្លាប់របស់ប្រជាជននៅជនបទ។
- ការកំហិតទៅលើការផ្សព្វផ្សាយ សារជាតុគីមីប្រើក្នុងវិស័យកសិកម្ម។

កម្មវិធី CAVAC បានធ្វើការស្រាវជ្រាវទៅលើទម្លាប់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់ប្រជាជន នៅតាមជនបទដើម្បីស្វែងយល់ថាហេតុអ្វីបានជាពួកគេមិនចូលចិត្តមើលកម្មវិធីដែលផលិតឡើងសម្រាប់ពួកគេ។ គោលដៅចំបង គឺដើម្បីសម្របសម្រួលការផលិតកម្មវិធីដើម្បីអោយដឹង ថាកម្មវិធីកសិកម្ម អាចទាក់ទាញទស្សនិកជន និងអាចប្រកួតប្រជែងជាមួយនឹងកម្មវិធីផ្សេងទៀតបានដែរ ឬទេ។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធី CAVAC ចាំបាច់ត្រូវ ៖

- ធានាថាក្រុមហ៊ុនផ្សព្វផ្សាយ ពាណិជ្ជកម្ម និងអ្នករៀបចំកម្មវិធីមានរាល់ព័ត៌មានអំពីទស្សនិកជន និងចំណង់ចំណូលចិត្ត។
- សម្របសម្រួលក្នុងការផលិតកម្មវិធីកសិកម្ម និងការអភិវឌ្ឍជនបទប្រកបដោយគំនិតថ្មៃប្រឌិតថ្មី និងមានគុណភាពដែលអាចធ្វើពាណិជ្ជកម្មប្រកួតប្រជែងបាន។

ការស្រាវជ្រាវរបស់កម្មវិធី CAVAC បង្ហាញថា កសិករជាទស្សនិកជនដែលមានចំនួនច្រើន និងមានតម្លៃ ហើយថាប្រជាជននៅជនបទនៅក្នុងប្រទេសកម្ពុជាមិនមែនសុទ្ធតែក្រីក្រដូចៗគ្នានោះទេ។ ក្រុមហ៊ុន ស្រាវជ្រាវប្រព័ន្ធផ្សព្វផ្សាយ នាពេលឥឡូវនេះ បានបញ្ចូលសហគមន៍ជនបទទៅក្នុងការ អង្កេតរបស់ពួកគេ។ កម្មវិធី CAVAC បានជួយផ្តល់ថវិកាដល់ការផលិតខ្សែរឿងដែអូភាគសម្រាប់ទូរទស្សន៍ដ៏មានប្រជាប្រិយភាពមួយដែលរឿងដែអូនោះនិយាយពាក់ព័ន្ធនឹងបញ្ហាជនបទ ដូចជាការប្រើប្រាស់ថ្នាំកសិកម្មជាដើម។ ខ្សែរឿងដែអូដែលមាន ២៦ភាគនេះ ត្រូវបានជ្រើសរើសយកមក ចាក់ផ្សាយនៅរដូវកាលទីពីរ។

ការអង្កេតទៅលើ លទ្ធផលរបស់កម្មវិធីបានបង្ហាញថាមានកសិករចំនួនប្រហែល ២០០.០០០នាក់ បាន ឬគិតថាពួកគេនឹងផ្លាស់ប្តូរការអនុវត្តបច្ចេកទេសកសិកម្មរបស់ពួកគេ ដោយសារតែកម្មវិធីនេះ។

### ៥. បរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្ម

នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ការគាំទ្រសៀវភៅណែនាំ របៀបប្រើប្រាស់ថ្នាំកសិកម្ម បានធ្វើឲ្យក្រុមហ៊ុនទាំងនោះធ្វើការបណ្តុះ បណ្តាលកសិករ ហើយបានក្លាយជាជំហានមួយ ដ៏ សំខាន់ នៅក្នុង ការបើក ផ្សារ។ យុទ្ធសាស្ត្រផ្សព្វផ្សាយ ថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ចូលយ៉ាងច្បាស់លាស់នូវតួនាទីនៃការផ្សព្វផ្សាយរបស់វិស័យឯកជន ដោយ

យោងទៅលើការងាររបស់កម្មវិធី CAVAC។ ចំពោះក្រសួងធនធានទឹក និងឧតុនិយម (MOW-RAM) គេបានចាត់ទុកធារាសាស្ត្រ CAVAC ថាជា ប្រព័ន្ធគំរូសម្រាប់ការស្រោចស្រព ដែលមានប្រសិទ្ធភាពខ្ពស់។ កម្មវិធី CAVAC ក៏បានរួមចំណែកផងដែរទៅដល់ទស្សនៈរបស់រដ្ឋាភិបាលលើសហគមន៍កសិករប្រើប្រាស់ទឹក និងអ្នកប្រកបរបរផ្តល់សេវាកម្មស្រោចស្រព។

កម្មវិធី CAVAC គឺជាតួអង្គដ៏សំខាន់នៅក្នុងបេសកកម្មដែលផ្តួចផ្តើមដោយក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) របស់ប្រទេសអូស្ត្រាលីរវាងប្រទេសចិន កម្ពុជា និងអូស្ត្រាលី។ ប្រទេសទាំងបីបានស្វែងរកកិច្ចសហប្រតិបត្តិការនាពេលអនាគត។ កម្មវិធី CAVAC ក៏បានគាំទ្រគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការវាយតម្លៃពូជស្រូវ និងផលប៉ះពាល់របស់ជំងឺមីទៅលើការកាប់បំផ្លាញព្រៃឈើ និងការរិចរិលជីវជាតិដី។

### មេរៀនដែលទទួលបាន

- សកម្មភាពបរិយាកាសអំណោយផលដល់ការធ្វើអាជីវកម្មដែលបានធ្វើផែនការជាមុននៅក្នុងឯកសាររៀបចំគម្រោងមិនទទួលបានជោគជ័យទេ។ ការចាប់យកឱកាសក្នុងពេលអនុវត្តន៍សកម្មភាព មានប្រសិទ្ធភាពជាង។
- កម្មវិធី CAVAC ទទួលបានជោគជ័យ ខ្លាំងនៅក្នុងការធ្វើឲ្យមាន ឥទ្ធិពលទៅលើដៃគូរបស់ CAVAC និងអ្នកពាក់ព័ន្ធផ្សេងៗទៀត តាមរយៈការធ្វើជាគំរូ និងបង្ហាញឲ្យឃើញថាអ្វីខ្លះដំណើរការល្អ។
- ការយល់ដឹងអំពីឱកាស និងឧបសគ្គ ដើម្បីធ្វើការផ្លាស់ប្តូរនៅក្នុងស្ថាប័ននានា គឺសំខាន់ខ្លាំងណាស់មុននឹងផ្តល់ការគាំទ្រណាមួយ។



## ធារាសាស្ត្រ

កម្មវិធី CAVAC ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង-មន្ទីរធនធានទឹក និងឧតុនិយម និងកសិករមូលដ្ឋាន ដើម្បីធ្វើការជ្រើសរើសសិក្សាប្លង់ និង សាងសង់ប្រព័ន្ធធារាសាស្ត្រ ចំនួន២០កន្លែង នៅក្នុងខេត្តគោលដៅចំនួនបីគឺ ខេត្តតាកែវ កំពត និងកំពង់ធំ។ បន្ទាប់ពីការអនុវត្តគម្រោងមួយរយៈពេលកន្លងមក ក្រុមការងារបានអភិវឌ្ឍ ប្រឡាយបេតុង និងបំពាក់ស្ថានីយ៍បូមទឹកដើរដោយចរន្តអគ្គិសនី ដែលជាប្រព័ន្ធធារាសាស្ត្របែបទំនើបនៅក្នុងប្រទេសកម្ពុជា។ នៅត្រឹមខែមិថុនា ឆ្នាំ ២០១៥ ប្រព័ន្ធទាំងនេះបានផ្គត់ផ្គង់ទឹកដល់កសិករចំនួនប្រមាណជា១៩.០០០គ្រួសារ លើផ្ទៃដីចំនួន ២០.០០០ ហិកតា នាពេលឥឡូវនេះទទួលបានទឹកមួយឆ្នាំពេញ។ ការទទួលបាន ទឹកនេះធ្វើឲ្យកសិករផលិតបានស្រូវបន្ថែមចំនួន ២១៨.០០០តោនជារៀងរាល់ឆ្នាំ ស្មើនឹងទឹកប្រាក់ប្រមាណជាចំនួន៤៣លានដុល្លារអាមេរិក។

នៅពេលគម្រោងបញ្ចប់ កសិករប្រហែលជាង ៥០% បានទទួលផល ហើយយើងរំពឹងទុកថាតួលេខនោះនឹងកើនឡើងរហូតដល់ ៨០ភាគរយនៅឆ្នាំបន្តបន្ទាប់ទៀត។

នៅជំហានដំបូង គម្រោងបានស្តារប្រព័ន្ធធារាសាស្ត្រខ្នាតតូច ជាប្រភេទប្រឡាយដី ប៉ុន្តែការងារប្រភេទនេះមិនបានផ្តល់លទ្ធផលល្អ ដូចការរំពឹងទុកដែលនាំអោយផលត្រឡប់នៃការវិនិយោគមានកម្រិតទាប និងមិនមាននិរន្តរភាព។

## និរន្តរភាពនៃធារាសាស្រ្ត

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមចម្បងៗ ក្នុងវិស័យប្រព័ន្ធធារាសាស្រ្តនៅក្នុងប្រទេសកម្ពុជាគឺ អាយុកាលក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្រ្តមានរយៈពេលខ្លី។ ហេតុដូច្នេះនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមការងារបានយកមេរៀនដែលទទួលបានពីការអនុវត្តកន្លងមក ដាក់បញ្ចូលទៅក្នុងការសិក្សាប្លង់ និងការអនុវត្តគម្រោង។ ដើម្បីធ្វើអោយប្រព័ន្ធធារាសាស្រ្តមាននិរន្តរភាព កម្មវិធី CAVAC បានអនុវត្តនូវវិធីសាស្រ្តដូចខាងក្រោម ៖

- ភ្ជាប់ប្រឡាយទៅនឹងប្រភពទឹកលើដីមិនចេះរីងស្ងួត ដូចជាទន្លេស្ទឹងជាដើម។
- ធ្វើការជាមួយសហគមន៍កសិករប្រើប្រាស់ទឹក ដែលមានឆន្ទៈខ្ពស់ និងមានភាពជាម្ចាស់លើប្រព័ន្ធប្រឡាយ។
- សាងសង់ប្រព័ន្ធធារាសាស្រ្តដែលចំណាយទាបទៅលើការជួសជុលថែទាំ។
- ធ្វើការជាមួយសហគមន៍កសិករប្រើប្រាស់ទឹកដែលមានស្រាប់តាមរយៈរូបភាព ការវិនិយោគថវិកាបង្គ្រប់ ។
- សហការជាមួយវិស័យឯកជន រួមមាន អ្នកម៉ៅការបូមទឹក ដើម្បីបង្កើនផ្ទៃដីស្រោចស្រព។
- ពិភាក្សា និងសហការណ៍ជិតស្និត ជាមួយក្រសួង មន្ទីរធនធានទឹក និងឧតុនិយម។
- សហការណ៍ជាមួយមន្ទីរជំនាញថ្នាក់ខេត្ត ដើម្បីរើសទីតាំងស្តារប្រព័ន្ធធារាសាស្រ្ត និងការគ្រប់គ្រងប្រព័ន្ធ។

បើទោះជាប្រព័ន្ធធារាសាស្រ្តប្រភេទសាមញ្ញ ឬស្មុគស្មាញ ក៏នៅតែតម្រូវអោយមានការជួសជុលថែទាំ។ ដូច្នេះកម្មវិធី CAVAC បានវិនិយោគយ៉ាងច្រើនទៅលើការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក និងនៅតែបន្តការគាំទ្រសហគមន៍ទាំងផ្នែកបច្ចេកទេស និងការកែលម្អប្រព័ន្ធក្រោយការសាងសង់បានបញ្ចប់១ទៅ២ឆ្នាំ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់ និងប្រព័ន្ធធារាសាស្រ្តទាំងមូលអាចប្រើប្រាស់បាន ក្នុងរយៈពេលយ៉ាងហោច១០ឆ្នាំទៅមុខទៀត។



## សហគមន៍កសិករប្រើប្រាស់ទឹក

ក្រោយពីការសាងសង់ប្រព័ន្ធធារាសាស្រ្តត្រូវបានបញ្ចប់ សហគមន៍កសិករប្រើប្រាស់ទឹក(ស.ក.ប.ទ) ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតដោយកសិករ ដើម្បីធ្វើការគ្រប់គ្រង និងជួសជុលថែទាំប្រឡាយ។ មានប្រព័ន្ធដែលកម្មវិធី CAVAC បានស្តារមួយចំនួនមានស.ក.ប.ទ រួចជាស្រេច ប៉ុន្តែភាគច្រើនជាប្រព័ន្ធធារាសាស្រ្តដែលបានស្តារ មិនមានសហគមន៍នោះទេដែលតម្រូវអោយមានការបង្កើតស.ក.ប.ទថ្មី ។ ការបង្កើតស.ក.ប.ទ គឺស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលតម្រូវអោយស.ក.ប.ទ ចុះបញ្ជីជាមួយនឹងមន្ទីរធនធានទឹក និងឧតុនិយមថ្នាក់ខេត្ត ហើយការចុះបញ្ជីបែបនេះ ធ្វើឲ្យស.ក.ប.ទមានសិទ្ធិស្នើសុំថវិកាពីរដ្ឋាភិបាលសម្រាប់ការជួសជុលថែទាំ។

ការចូលរួមរបស់កសិករគឺមានភាពចាំបាច់ណាស់ចាប់តាំងពីគម្រោងទើបចាប់ផ្តើមដំបូង ជាពិសេសការចូលរួមបរិច្ចាកដីធ្វើប្រឡាយ និងការចូលរួមបង់ថ្លៃវិភាគទានសេវាប្រើប្រាស់ទឹក ក្រោយប្រព័ន្ធសាងសង់រួច ទៅអោយ ស.ក.ប.ទ និងភាពជាម្ចាស់កម្មសិទ្ធិត្រូវពន្យល់ឲ្យបានច្បាស់លាស់ទៅដល់ពួកគាត់តាំងពីគម្រោងចាប់ផ្តើមដំបូងមកម្ល៉េះ។

ស.ក.ប.ទ ត្រូវទទួលបន្ទុកក្នុងការគ្រប់គ្រង និងការជួសជុលថែទាំ រួមមានប្រឡាយ ម៉ូទ័របូមទឹក និងសំណង់សិល្បការ នៅក្នុងប្រព័ន្ធទាំងមូល។ ដើម្បី អោយស.ក.ប.ទ មានសមត្ថភាពក្នុងការបំពេញតួនាទីនេះបាន កម្មវិធី CAVAC សហការជាមួយនឹងមន្ទីរធនធានទឹក និងឧតុនិយមថ្នាក់ខេត្ត បានផ្តល់ការបណ្តុះបណ្តាលតាមរយៈរូបភាពអនុវត្តន៍ផ្ទាល់ជាមួយពួកគាត់ ជាពិសេសសម្រាប់ប្រព័ន្ធធារាសាស្រ្តដែលមានស្មុគស្មាញ ការគាំទ្ររយៈពេលច្រើនឆ្នាំបន្ទាប់ពីការសាងសង់បានបញ្ចប់។ នៅពេលការគាំទ្រត្រូវ បានបញ្ចប់ ប្រព័ន្ធធារាសាស្រ្តរបស់កម្មវិធី CAVAC ត្រូវប្រគល់ជូនមន្ទីរធនធានទឹក និងឧតុនិយមថ្នាក់ខេត្ត ។

# គម្រោងធារាសាស្ត្រកម្មវិធី CAVAC ឆ្នាំ ២០១០--២០១៥

## ខេត្តកំពង់ធំ

- ត្នោតជុំ ២០១១/១៤
- អង្គគោ + ការលើកកម្ពស់ ២០១១/១២/១៤/១៥
- បឹងល្មៀស ២០១៤/១៥
- ប្រឡាយ ៦ មករា ១, ២ និង៣ ២០១៣/១៤




## ខេត្តកំពត

- ព្រៃទន្លេ, ២០១០
- អូកក់, ២០១១/១២/១៤
- ស្បូវអណ្តែត, ២០១១/១៤
- ត្នោត, ២០១១/១៤
- ស្ពានតូច, ២០១២/១៣
- ព្រៃលើ, ២០១២
- ហៃសូន, ២០១៣/១៤
- ចម្លងជ្រៃ, ២០១៣/១
- អាងទឹក, ៧៧,២០១៣/១៤

## ខេត្តតាកែវ

- ក្រពុំឈូក, ២០១០
- ខ្វែងតាយី, ២០១១
- ទំនប់លោក, ២០១១/១២/១៣
- ព្រៃរំដេង, ២០១២
- សូហង់, ២០១១/១២
- រកាឈូក, ២០១៣/១៤
- វត្តថ្មី (ធម្មវិន័យ), ២០១៤/១៥

# ការបង្កើតវិធីសាស្ត្រថ្មីសម្រាប់ធារាសាស្ត្រនៅកម្ពុជា

វិធីសាស្ត្ររបស់កម្មវិធី CAVAC ផ្នែកប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រង ទឹកបាន ផ្លាស់ប្តូរ ជា បន្តបន្ទាប់ ក្នុងកំឡុងពេលអនុវត្ត កម្មវិធី តាមរយៈ ការយក មេរៀន ដែល ទទួលបាន ពី ការអនុវត្តមក កែលម្អ និងផ្តោតលើនិរន្តរភាព និងការអោយផលត្រឡប់នៃការវិនិយោគ។ ការស្តារ ប្រព័ន្ធធារាសាស្ត្រនៅក្នុង ប្រទេស កម្ពុជា ភាគច្រើន គឺជា ប្រភេទប្រឡាយដី ហើយដំបូងឡើយកម្មវិធី CAVAC ក៏បានស្តារ ប្រព័ន្ធបែបនេះដែរ។ ប៉ុន្តែនៅក្នុង កំឡុងពេលអនុវត្តគម្រោង សេដ្ឋកិច្ចនៃកសិកម្មបានផ្លាស់ប្តូរ ដោយសារស្រូវបានធ្លាក់ថ្លៃ ហេតុដូច្នេះក៏ប៉ះពាល់ដល់ប្រាក់ចំណេញរបស់កសិករ។ ប្រភេទប្រឡាយដីមិនត្រឹមតែតម្រូវអោយកសិករបរិច្ចាកដីច្រើននោះទេ ហើយវាក៏ជាកត្តាដែលធ្វើឲ្យកសិករពុំមានលទ្ធភាពក្នុងការចូលរួមបង់ប្រាក់វិភាគទានសេវាប្រើប្រាស់ទឹក ដោយសារប្រព័ន្ធនោះមិនអាចកាត់បន្ថយការចំណាយលើការបូមទឹករបស់គាត់បានឡើយ ។

នៅឆ្នាំ ២០១៣ កម្មវិធី CAVAC បានចាប់ផ្តើមសិក្សាប្លង់តាមបែបទំនើបកម្ម ហើយនៅក្នុងឆ្នាំ២០១៤ កម្មវិធី CAVAC បានសាងសង់ប្រឡាយបេតុងជាលើកដំបូង។ គួរបញ្ជាក់ផងដែរថា ប្រឡាយបេតុង និងស្ថានីយ៍បូមទឹកមិនមែនជារឿងថ្មីសម្រាប់ប្រទេសកម្ពុជានោះទេ។ តែប្រព័ន្ធធារាសាស្ត្របេតុងខ្នាតតូចនិងមធ្យម និងស្ថានីយ៍បំពាក់ដោយម៉ូទ័រអគ្គិសនី ពុំធ្លាប់មានពីមុននៅក្នុងប្រទេសកម្ពុជាឡើយ។ វិធីសាស្ត្រថ្មីដែលកម្មវិធី CAVAC សាងសង់ប្រឡាយនេះបានបង្កើននិរន្តរភាពនៃប្រឡាយ ដោយផ្តល់នូវអត្ថប្រយោជន៍ចំនួនបីសំខាន់៖

- ប្រឡាយបេតុង ជួយ កាត់បន្ថយការបរិច្ចាកដីរបស់កសិករ ដោយសារមុខកាត់តូចជាងប្រឡាយដី។
- ប្រឡាយបេតុងមានអាយុកាលប្រើប្រាស់បានរហូតដល់១៥ ទៅ២០ឆ្នាំ យូរ ជាង ប្រឡាយ បែប ប្រពៃណី ដែលមាន អាយុកាល ប្រើប្រាស់ត្រឹមតែ៥ទៅ៧ឆ្នាំប៉ុណ្ណោះ។
- កាត់បន្ថយការចំណាយទៅលើការជួសជុលថែទាំ។

ការវិនិយោគលើប្រព័ន្ធធារាសាស្ត្របែបទំនើបនេះគឺការចំណាយខ្ពស់បើប្រៀបធៀប ទៅនឹងប្រឡាយដី ពីព្រោះប្រឡាយបេតុង និងម៉ាស៊ីនបូមទឹកមានតម្លៃថ្លៃ។ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្របែបទំនើបនេះ ជារឿងថ្មីសម្រាប់ក្រុមហ៊ុនសាងសង់ កសិករមិនដែលបានឃើញ ហើយចំណាយក្នុងការទិញ និងការនាំចូលម៉ូទ័រក៏ពិបាកនឹងធ្វើការប៉ាន់ស្មានតម្លៃ។ ទោះបីជាមានហានិភ័យទាំងនេះក្តី តម្លៃសាងសង់មានភាពខុសគ្នា ប្រព័ន្ធដែលបានសាងសង់រួចនៅក្នុងឆ្នាំ ២០១៤ និង២០១៥ ត្រូវបានចាត់ទុកថាជាប្រព័ន្ធគំរូមួយសម្រាប់ប្រព័ន្ធធារាសាស្ត្រនៅក្នុងពេលអនាគតផងដែរ។

### កម្មវិធី CAVAC – មេរៀនទូទៅដែលទទួលបានពីការអនុវត្ត

បរិបទសង្គមសេដ្ឋកិច្ចកម្ពុជាមានភាពស្មុគស្មាញ និងប្រែប្រួលខ្លាំងពេក មិនអាចអនុវត្តដំណោះស្រាយដែលបានកំណត់ទុកជាមុនបានឡើយ។ វិធីសាស្ត្រគ្រប់គ្រងដែលមានភាពបត់បែន បានផ្តល់ឱកាសដល់ការកែលម្អតាមរយៈមេរៀនដែលទទួលបានពីការអនុវត្ត និងកែតម្រូវជាបន្តបន្ទាប់នូវសកម្មភាពការងារ។ ការងារនេះមានផលវិបាកដូចខាងក្រោម៖

១. **បុគ្គលិកក្នុងស្រុកគឺជាកត្តាកំណត់ដ៏សំខាន់ធំបំផុតស្រមាប់ភាពជោគជ័យ៖** ពួកគាត់គឺជាភ្នែក និងត្រចៀកនៃកម្មវិធី ពោលគឺពួកគាត់ជាអ្នកស្វែងរកឱកាស និងជំរុញការអនុវត្ត។ ពួកគាត់ជា បុគ្គលិកដែលមានជំនាញខាងវិភាគ និងគំនិតច្នៃប្រឌិតខ្ពស់ ដែលជំនាញទាំងនេះមានភាពចាំបាច់ យកមកអនុវត្តផ្ទាល់ និងអាចចែករំលែកទៅក្រុមការងារផ្សេងទៀតតាមរយៈការបង្រៀន ឬផ្តល់ជំនាញបច្ចេកទេស នៅពេលដែលត្រូវការចាំបាច់។ កម្មវិធី CAVAC បានរើសបុគ្គលិកដែលមានសមត្ថភាពវិភាគខ្លាំងបំផុតដែលខ្លួនអាចស្វែងរកបាននៅក្នុងទីផ្សារការងារ បើមិនដូច្នោះគម្រោងនឹងអាច មានបញ្ហាជាច្រើនកើតឡើង។ ដូច្នេះមេរៀនដែលទទួលបានគឺត្រូវកំណត់អាទិភាពសមត្ថភាពនៃក្រុមការងារ ដោយមិនសំដៅតែលើតែជំនាញ និងសញ្ញាប័ត្រតែមួយមុខនោះទេ។

២. **វប្បធម៌ និងរចនាសម្ព័ន្ធរៀបចំរបស់កម្មវិធី ត្រូវជំរុញឲ្យមានការរៀន និងការអភិវឌ្ឍ៖** ការបង្កើតឲ្យមានបរិយាកាសស្វ័យរិះគន់លើការសិក្សា ប្រាកដប្រជាតម្រូវឲ្យមានការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ពិតប្រាកដ។ កម្មវិធី CAVAC វិនិយោគយ៉ាងខ្លាំងក្លាទៅលើការបង្កើតឲ្យមានវប្បធម៌នេះនៅកន្លែងធ្វើការ ហើយនៅតែទទួលបានជោគជ័យត្រឹមតែ៨០%ប៉ុណ្ណោះ។

៣. **ប្រព័ន្ធគ្រប់គ្រងកម្មវិធីត្រូវមានសមត្ថភាពឆ្លើយតបយ៉ាងរហ័សទៅនឹងបញ្ហាដែលអាចធ្វើឲ្យរាក់ដំណើរការ៖** កម្មវិធីត្រូវមានសមត្ថភាពបត់បែនសកម្មភាពជាបន្តបន្ទាប់ ដោយមិនចាំបាច់មានរចនាសម្ព័ន្ធគ្រប់គ្រងដែលដាក់កំហិតឡើយ។ វាតម្រូវឲ្យមានការគ្រប់គ្រងបែបបន្សាំ និងភាពបត់បែនពីក្រុមហ៊ុនសាងសង់ និងម្ចាស់ជំនួយ។

៤. **សកម្មភាពការងារទីផ្សារ និងអន្តរាគមន៍ត្រូវគ្រប់គ្រងដើម្បីទទួលបានជោគជ័យ៖** ដោយចាប់ផ្តើមជាមួយនឹងសកម្មភាពការងារទូទៅ រួចបញ្ឈប់អន្តរាគមន៍ដែលមិនសូវទទួលបានជោគជ័យ ហើយនិងធ្វើការបែងចែកធនធានឡើងវិញចំពោះអន្តរាគមន៍ណាដែលមានឥទ្ធិពលជាអតិបរមា។ សកម្មភាពការងាររបស់កម្មវិធី CAVAC បានវិវត្តជាបន្តបន្ទាប់ ហើយប្រសិនបើគ្មានសមត្ថភាពនេះទេ នោះកម្មវិធី CAVAC ក៏មិនអាចទទួលបានជោគជ័យឡើយ។





## ការស្ពានបន្តពីកេរដំណែលរបស់កម្មវិធី CAVAC

បន្ទាប់ពីកម្មវិធី CAVAC ទទួលបានជោគជ័យមក រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី បានព្រមព្រៀងគ្នា ថា កម្មវិធី CAVAC នឹងបន្តទៅដំណាក់កាលទី ពីរទៀត។ កម្មវិធី CAVAC ចាប់ផ្តើមពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២១។ កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីសម្រេចគោលដៅចំនួនពីរ៖

- បង្កើនប្រាក់ចំណូលដល់កសិករដែលមានដីតូច។
- បង្កើនពាណិជ្ជកម្មអង្ករ និងដំណាំផ្សេងៗទៀត។

ដំណាក់កាលទីពីរនៃកម្មវិធី CAVAC បានពង្រីកវិសាលភាព និងថវិការបស់ខ្លួន ហើយបច្ចុប្បន្នចែកជាបីផ្នែកសំខាន់ៗ៖

**១. ផលិតភាព និងពិពិធកម្ម** បន្តធ្វើការទៅលើទីផ្សារជី និងថ្នាំកសិកម្ម ព្រមទាំងពិនិត្យទៅលើពិពិធកម្មដំណាំផ្សេងៗទៀត រួមមានដំឡូងមី សណ្តែក និងពោត។

**២. ការគ្រប់គ្រងធារាសាស្ត្រ និងទឹក** បានកសាងនូវប្រព័ន្ធធារាសាស្ត្រចំនួន២០កន្លែងរួចហើយ ក្នុងរយៈពេលអនុវត្ត



កម្មវិធី ហើយនឹងបន្តសាងសង់ប្រព័ន្ធធារាសាស្ត្រចំនួនពីរទៀតនៅក្នុងឆ្នាំ២០១៧ ក៏ដូចជាបន្តគាំទ្រសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងការប្រើប្រាស់ និងការថែទាំប្រព័ន្ធទាំងនេះ។

**៣. វិស័យពូជ និងនាំចេញអង្ករ** គឺជាផ្នែកថ្មីមួយដែលត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើការនាំចេញអង្ករ និងកំពុងជួយលើកកម្ពស់ប្រភេទពូជស្រូវនានាដើម្បីគាំទ្រដល់គោលដៅនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា។ ផ្នែកនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) អគ្គនាយកដ្ឋានកសិកម្ម ក្រុមហ៊ុនផលិតពូជស្រូវ សហព័ន្ធអង្ករកម្ពុជា និងតួអង្គទីផ្សារសំខាន់ៗផ្សេងៗទៀត។

កម្មវិធី CAVAC ទទួលបានការគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយក្រុមហ៊ុន Cardno

**ទំនាក់ទំនង CAVAC ៖**
អគារ Emerald ជាន់ទី២&៣
អគារលេខ៦៤ មហាវិថីនរោត្តម (កែងផ្លូវលេខ ១៧៨)
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ៖ ១២៣៩
គេហទំព័រ៖ www.cavackh.org

**ទំនាក់ទំនង Cardno ៖**
Level 4
501 Swanston Street
Melbourne
Victoria Australia 3000
www.cardno.com/internationaldevelopment

